អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន
# របស់សហព្រះរាជអាជ្ញាអន្តរជាតិ

ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងក្នុងការលាលែងពីមុខតំណែងរបស់ខ្ញុំ ក្នុងឋានៈជា សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់តាំងពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ នេះតទៅ ដោយមកពីមូលហេតុចាំបាច់ផ្ទាល់ខ្លួន និងគ្រួសារ ។

វាជាបុព្វសិទ្ធិមួយដ៏ធំធេងបំផុតចំពោះមុខវិជ្ជាជីវៈរបស់ខ្ញុំ ដែលខ្ញុំមានឱកាសបាននាំយកមកនូវយុត្តិធម៌មួយចំនួនសម្រាប់ជនរងគ្រោះនានានៃឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម ។ ខ្ញុំនៅតែជឿជាក់ថា សេចក្តីសង្ឃឹមរបស់កម្ពុជាចំពោះអនាគតមួយដ៏ល្អប្រសើរ គឺមួយផ្នែកស្ថិតនៅលើគណនេយ្យភាពដ៏ពិតប្រាកដមួយទៅលើឧក្រិដ្ឋកម្មនានា ។ បុគ្គលិករបស់ខ្ញុំ និងរូបខ្ញុំផ្ទាល់ បានប្រឹងប្រែងព្យាយាមចូលរួមចំណែកនៅក្នុងគោលដៅនោះដោយអស់ពីលទ្ធភាពរៀងៗខ្លួន នៅក្នុងយុត្តាធិការរបស់ពួកយើងខ្ញុំ ។ ខ្ញុំមានក្តីសង្ឃឹមថា សហព្រះរាជអាជ្ញារង គឺលោក វីលាម ស្មីត និងបុគ្គលិករបស់ខ្ញុំ រួមជាមួយនឹងសហការីកម្ពុជារបស់យើង នឹងនៅតែបន្តការងារនេះតទៅទៀត នៅក្រោយពេលការចាកចេញរបស់ខ្ញុំ ។ សេចក្តីសម្រេចរបស់ខ្ញុំត្រូវបានធ្វើឡើង ក្រោយពីមានការពិចារណា និងមានការពិគ្រោះយោបល់យ៉ាងយូរអស់ជាច្រើនខែ ដូច្នេះហើយខ្ញុំជឿជាក់ថាការងាររបស់ការិយាល័យខ្ញុំ នឹងនៅតែបន្តទៅមុខទៀតដោយប្រើអស់នូវកម្លាំងកាយ-ចិត្តដូចមុនដដែល ទាំងនៅក្នុង និងក្រោយអម្លុងពេលអន្តរកាលនេះ ។ ដំណើរការជាផ្លូវការនៃការតែងតាំងអ្នកដែលត្រូវមកជំនួសរូបខ្ញុំកំពុងតែដំណើរការទៅមុខ ហើយកិច្ចការនេះនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗនេះ ។

រូបខ្ញុំផ្ទាល់ ក៏ដូចជាគ្រួសាររបស់ខ្ញុំដែរ ត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅនៅក្នុងប្រទេសកម្ពុជា ហើយពួកយើងខ្ញុំក៏បានហៅប្រទេសនេះថាជាស្រុកកំណើតរបស់ខ្លួនអស់រយៈពេលបីឆ្នាំមកហើយ ។ ហេតុនេះហើយយើងមានកតញ្ញូតាធម៌ជារៀងរហូតចំពោះប្រជាជនកម្ពុជា ។

យោងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ហើយនិងវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះនេះ ខ្ញុំបានជូនយោបល់ទៅអគ្គលេខាធិការនៃអង្គសហប្រជាជាតិ និងកិច្ចប្រជុំពេញអង្គរបស់អ.វ.ត.ក តាមរយៈប្រធាននៃកិច្ចប្រជុំពេញអង្គនេះរួចហើយអំពីសេចក្តីសម្រេចរបស់ខ្ញុំនេះ ។

---ចប់---